ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

Ministry of Commerce

No. ៣៨៩៦ MOC / SM 2011

THE GARMENT MANUFACTURERS ASSOCIATION IN CAMBODIA (GMAC)
THE SECRETARIAT
IN
No :....416....
Date:09.09.11 Time:9:30
For :....GMAC....

# ប្រកាស

## ស្ដីពី

## ការគ្រប់គ្រងកិច្ចសន្យាជួលផលិតបន្ត (Sub-Contract)
## ក្នុងវិស័យឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ និងវាយនភ័ណ្ឌ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតក្រសួង ពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែសីហា ឆ្នាំ ២០០៧ ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម

-យោងសារាចរណែនាំលេខ ០៦ សរណន ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៥ ស្ដីពីការអនុវត្តន៏គម្រោងរបស់អង្គការពលកម្មអន្តរជាតិ ដើម្បីធ្វើឱ្យប្រសើរឡើងដល់រោងចក្រកម្ពុជា ក្នុងវិស័យវាយនភ័ណ្ឌ និងសម្លៀកបំពាក់

-យោងប្រកាសអន្តរក្រសួងលេខពិសេសអន្តរស្ថាប័ន ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ២០១១ ស្ដីពីការគ្រប់គ្រងកិច្ចសន្យា ជួលផលិតបន្ត ក្នុងឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ វាយនភ័ណ្ឌ និងស្បែកជើង

-យោងតាមស្ថានការណ៍ចាំបាច់របស់ទីផ្សារផលិតផលសម្លៀកបំពាក់

## សម្រេច

**ប្រការ ១:** រាល់កិច្ចសន្យាជួលផលិតបន្ត (Sub-contract) បានធ្វើនៅតាមបណ្ដារោងចក្រកាត់ដេរសម្លៀកបំពាក់ និងវាយនភ័ណ្ឌ ចាំបាច់ត្រូវជូនដំណឹងមកអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ នៃក្រសួងពាណិជ្ជកម្ម ។

**ប្រការ ២:** រាល់កិច្ចសន្យាដែលបានធ្វើរវាងបណ្ដារោងចក្រជាមួយ អ្នកទទួលផលិតបន្តពុំចាំបាច់មកសុំការអនុញ្ញាតពី ក្រសួងពាណិជ្ជកម្ម ឬបង់កម្រៃនៅពេលជូនដំណឹងមកក្រសួងពាណិជ្ជកម្មឡើយ ក្រៅពីបិទតែមប្រិយ៍តម្លៃ ៥០០ រៀល រួមនឹងចុះលេខ និងកាលបរិច្ឆេទលិខិតចូលលើសេចក្ដីជូនដំណឹងរបស់រោងចក្រ ។

**ប្រការ ៣:** មានតែរោងចក្រដែលជាសមាជិកសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) ដែលបានចុះបញ្ជីក្រោមគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា តាមគំរូសេចក្ដីប្រកាសដែលកំណត់ដោយក្រសួងពាណិជ្ជកម្ម ទើបមានសិទ្ធិចុះកិច្ចសន្យាផលិតបន្តបាន ។

**ប្រការ ៤:** រោងចក្រដែលមានសិទ្ធិចុះកិច្ចសន្យាផលិតបន្ត ត្រូវប្រកាសពីសមត្ថភាពផលិតកម្មរបស់ខ្លួន ប្រចាំត្រីមាសក្នុងឆ្នាំនីមួយៗមកអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ នៃក្រសួងពាណិជ្ជកម្ម ជាប្រចាំ ។



ក្រសួងពាណិជ្ជកម្ម
លេខ ១៩-៦១ ផ្លូវក្រសួងពាណិជ្ជកម្ម (ផ្លូវ១១៣បេ)
ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨៦៦ ០៨៨/៨៦៦ ៨៧៨
ទូរសារលេខ: (៨៥៥) ២៣ ៨៦៦ ៨២៥
អ៊ីម៉ែល: moccab@moc.gov.kh

**ប្រការ ៥:** លេខាធិការដ្ឋានរបស់គណៈកម្មការអន្តរក្រសួង រវាងក្រសួងពាណិជ្ជកម្ម ក្រសួងមហាផ្ទៃ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបញ្ជូនមន្ត្រីក្រោមឱវាទទៅធ្វើការវាយតម្លៃលើសមត្ថភាពផលិតកម្មដែលបានរាយការណ៍ ដោយរោងចក្រនីមួយៗ និងធ្វើការតាមដានការអនុវត្តន៍កិច្ចសន្យាជួលផលិតបន្ត ។

**ប្រការ ៦:** លេខាធិការដ្ឋាននៃគណៈកម្មការអន្តរក្រសួងមានភារកិច្ចត្រូវចូលរួមតាមដាន និងស្រាវជ្រាវការអនុវត្តន៍កិច្ចសន្យាជួល ផលិតបន្ត និងប្រមូលឯកសារព្រមទាំងភស្តុតាងនានា ដើម្បីផ្ញើជូនគណៈកម្មការធ្វើការពិនិត្យពិចារណា និងដាក់ពិន័យ ចំពោះរោងចក្រដែលប្រព្រឹត្តល្មើស ។

**ប្រការ ៧:** ក្នុងករណីរោងចក្រអនុវត្តកិច្ចសន្យាជួលផលិតបន្តមិនបានប្រកាសជូនដំណឹង មកអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិនៃក្រសួងពាណិជ្ជកម្មទេនោះ នឹងត្រូវទទួលពិន័យផ្អាកការនាំចេញរយៈពេល ០១ សប្តាហ៍ ។ ក្នុងករណីមិនរាងចាលរោងចក្រនៅបន្តបំពានជាលើកទី ២ នឹងត្រូវផ្អាកការនាំចេញរយៈពេល ០១ ខែ ។ ក្នុងករណី ប្រព្រឹត្តិល្មើសជាលើកទី ៣ នឹងត្រូវផ្អាកការនាំចេញរយៈពេល ០៣ ខែ ។

**ប្រការ ៨:** រោងចក្រដែលពុំមែនជាសមាជិកសមាគមរោងចក្រកាត់ដេរនៅកម្ពុជា មិនត្រូវបានអនុញ្ញាតឱ្យចុះកិច្ចសន្យាផលិតបន្តជាមួយរោងចក្រដែលបានចុះបញ្ជីជាសមាជិកសមាគមរោងចក្រកាត់ដេរនៅកម្ពុជាឡើយ ។

**ប្រការ ៩:** ក្នុងករណីរោងចក្រដែលបានចុះបញ្ជីជាសមាជិកសមាគមរោងចក្រកាត់ដេរនៅកម្ពុជា ហើយអនុវត្តកិច្ចសន្យាជួលផលិតបន្តជាមួយរោងចក្រក្រៅប្រព័ន្ធចុះបញ្ជីនោះ នឹងត្រូវទទួលពិន័យដោយផ្អាកការនាំចេញរយៈពេល ០២ សប្តាហ៍ ។ ក្នុងករណីបំពានជាលើកទី ២ នឹងត្រូវផ្អាកការនាំចេញរយៈពេល ០១ ខែ ។ ក្នុងករណីបំពាន ត្រូវបានរកឃើញជាលើកទី ៣ នឹងត្រូវដកហូតសិទ្ធិក្នុងការនាំចេញហើយត្រូវលុបឈ្មោះចេញពីបញ្ជីមានសិទ្ធិនាំចេញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មជាស្ថាពរ ។

**ប្រការ ១០:** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ១១:** នាយិកាខុទ្ទកាល័យ អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងពាណិជ្ជកម្ម ត្រូវទទួលបន្ទុកអនុវត្តសេចក្តីប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១១

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**ចម្លងជូន :**
- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ខុទ្ទកាល័យលោកជំទាវឧបនាយករដ្ឋមន្ត្រីប្រចាំការ **ម៉ែន សំអន**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា
- សមាគមរោងចក្រកាត់ដេរនៅកម្ពុជា " ដើម្បីផ្សព្វផ្សាយ "
- គ្រប់តំបន់សេដ្ឋកិច្ចពិសេសក្នុងព្រះរាជាណាចក្រកម្ពុជា
- ដូចប្រការ ១១ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ



ក្រសួងពាណិជ្ជកម្ម
លេខ ១៩-៦១ ផ្លូវក្រសួងពាណិជ្ជកម្ម (ផ្លូវ១១៣បេ)
ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨៦៦ ០៨៨/៨៦៦ ៨៧៨
ទូរសារលេខ: (៨៥៥) ២៣ ៨៦៦ ៨២៥
អ៊ីម៉ែល: moccab@moc.gov.kh